វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ការនាំចេញរបស់កម្ពុជាទៅកាន់អាមេរិកកើនឡើងនៅក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ
- ប្រទេសថៃកាត់បន្ថយអត្រាការប្រាក់ដែលមានការផ្លាស់ប្តូរគួរអោយភ្ញាក់ផ្អើល
- សហរដ្ឋអាមេរិកអោយឈ្មោះប្រទេសចិនថាជា "អ្នកពង្វក់រូបិយប័ណ្ណ" ដែលកាន់តែជម្រុញឲ្យមានសង្គ្រាមពាណិជ្ជកម្ម

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញរបស់កម្ពុជាទៅកាន់អាមេរិក បានកើនឡើងនៅក្នុងឆមាសទី១ ក្នុងឆ្នាំ២០១៩នេះ

យោងតាមទិន្នន័យពាណិជ្ជកម្មអន្តរជាតិចុងក្រោយរបស់ការិយាល័យជំរឿនអាមេរិកបានអោយដឹងថា ការនាំចេញរបស់កម្ពុជាទៅកាន់អាមេរិកបានកើនឡើង៣០% នៅក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ បើធៀបទៅនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៨។ អាមេរិកបានទិញទំនិញកម្ពុជា ដែលមានតម្លៃជាទឹកប្រាក់២,២ប៊ីលានដុល្លារ ក្នុងរយៈពេល៦ខែនេះ ខណៈដែលកម្ពុជាបាននាំចូលទំនិញពីអាមេរិក ចំនួន ០,៣ ប៊ីលានដុល្លារ។ ពាណិជ្ជកម្មរវាងប្រទេសទាំងពីរ មានតម្លៃសរុបប្រមាណ ២,៥ប៊ីលានដុល្លារ។

ការចូលរួមចំណែកដ៏សំខាន់មួយនៃការកើនឡើងនេះ គឺដោយសារតែកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) ដែលផ្តល់ដោយអាមេរិកនៅក្នុងឆ្នាំ២០១៦ អនុញ្ញាតឱ្យកម្ពុជានាំចេញទំនិញសម្រាប់ការធ្វើដំណើរដូចជា៖ វ៉ាលី កាបូបស្ពាយ កាបូបដៃ និងកាបូបដៃ មនុស្សប្រុស ទៅអាមេរិក ជាមួយនឹងអត្ថប្រយោជន៍នៃការលើកលែងពន្ធ។ ទំនិញនាំចេញរបស់កម្ពុជា ក្រោមកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធទូទៅនេះ បានកើនឡើងពី៥០លានដុល្លារ ទៅ៤០០លានដុល្លារ នេះបើយោងតាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានចុះផ្សាយនៅក្នុងសារព័ត៌មានភ្នំពេញប៉ុស្តិ៍។

### តារាងប្រចាំសប្តាហ៍៖ ការចំណាយចរន្តថ្នាក់ជាតិ ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩

តារាងប្រចាំសប្តាហ៍នេះបង្ហាញពីថវិកាពីមួយឆ្នាំទៅមួយឆ្នាំ និងកំណើនប្រចាំឆ្នាំនៃចំណាយចរន្តថ្នាក់ជាតិនៅក្នុងត្រីមាសទី១ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩។ ចំណាយចរន្តថ្នាក់ជាតិបានកើនឡើងជាលំដាប់ពី ១ ៧៤៣ប៊ីលានរៀល

ក្នុងត្រីមាសទី១ឆ្នាំ២០១៦ ដល់ ២ ៨៦៦ប៊ីលានរៀល ក្នុងត្រីមាសទី១ឆ្នាំ ២០១៩ ជាមួយនឹងអត្រាកំណើនជាមធ្យម ១៩,២% ប្រចាំឆ្នាំ។ ទោះយ៉ាងណាក៏ដោយ កំណើនបានថយចុះគួរឱ្យកត់សម្គាល់នៅឆ្នាំនេះ មកប្រហែល ៣,៥% ។




ប្រភព៖ ច្បាប់ទូទាត់ថវិកាពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ការលក់ឡានរបស់ជប៉ុនទៅអោយកូរ៉េខាងត្បូងមានការធ្លាក់ចុះដោយសារតែភាពតានតឹងផ្នែកពាណិជ្ជកម្ម

ការលក់រថយន្តរបស់ជប៉ុននៅក្នុងប្រទេសកូរ៉េខាងត្បូងបានធ្លាក់ចុះ៣២% នៅក្នុងខែកក្កដា បើធៀបទៅនឹងខែមុន ដោយសារតែភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។

អ្នកប្រើប្រាស់របស់កូរ៉េខាងត្បូងបានចាប់ផ្តើមធ្វើពហិការមិនប្រើប្រាស់ផលិតផលរបស់ប្រទេសជប៉ុន ដើម្បីជាការឆ្លើយតបទៅនឹងការដាក់កំហិតរបស់លោកនាយករដ្ឋមន្ត្រីជប៉ុន Shinzo Abe ដែលបានដាក់ទៅលើប្រភេទផលិតផលដែលមានបច្ចេកវិទ្យាខ្ពស់របស់ជប៉ុន ដែលនាំចេញទៅកាន់កូរ៉េខាងត្បូង។

យោងទៅតាមសមាគមន៍អ្នកនាំចូល និងចែកចាយរថយន្តរបស់កូរ៉េ ដែលរាយការណ៍ដោយសារព័ត៌មានBloomberg ការចុះបញ្ជីយានយន្តរបស់ក្រុមហ៊ុនម៉ូតូហុងដា បានធ្លាក់ចុះ ៤២% ខណៈដែលសាជីវកម្មម៉ូទ័ររបស់ក្រុមហ៊ុនតូយូតាបានធ្លាក់ចុះ៣៨%។ គិតពីដើមឆ្នាំ ពីខែមករាដល់ខែកក្កដា ការលក់ឡានរបស់ជប៉ុនមានប្រមាណ៦,៧% បើធៀបទៅនឹងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន។

## ប្រទេសថៃកាត់បន្ថយអត្រាការប្រាក់ដែលមានការផ្លាស់ប្តូរគួរអោយភ្ញាក់ផ្អើល

ធនាគាររបស់រាជាណាចក្រថៃ បានកាត់បន្ថយអត្រាពន្ធគោលនយោបាយរបស់ខ្លួនចំនួន២៥ពិន្ទុគោល មកត្រឹម ១,៥% បើយោងតាមសារព័ត៌មាន Reuters ។ អ្នកវិភាគបានឯកភាពគ្នាស្ទើរតែទាំងស្រុងថានឹងគ្មានការផ្លាស់ប្តូរទេ។

ទស្សនៈវិស័យសម្រាប់សេដ្ឋកិច្ចរបស់ប្រទេសថៃមានភាពទន់ខ្សោយជាងមុនសម្រាប់ស្ថានភាពខ្លះ ប៉ុន្តែថ្មីៗនេះ សង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិន រួមជាមួយនឹងការបញ្ចុះតម្លៃរូបិយប័ណ្ណយ័នរបស់ចិនបានធ្វើអោយតម្លៃប្រាក់បាតរបស់ថៃមានការកើនឡើង។ ផលប៉ះពាល់នៃការពង្រឹងរូបិយប័ណ្ណសម្រាប់ការនាំចេញរបស់ថៃបានធ្វើឱ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។

# សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

## សហរដ្ឋអាមេរិកអោយឈ្មោះ ប្រទេសចិនថាជា "អ្នកពង្វក់រូបិយប័ណ្ណ" ដែលកាន់តែជម្រុញឲ្យមានសង្គ្រាមពាណិជ្ជកម្ម

សហរដ្ឋអាមេរិកបានហៅប្រទេសចិនថា ជាអ្នកគ្រប់គ្រងរូបិយប័ណ្ណ បន្ទាប់ពីធនាគារកណ្តាលចិនបានបញ្ចុះតម្លៃប្រាក់យន់ ដើម្បីឆ្លើយតបតបទៅនឹងពន្ធថ្មីរបស់អាមេរិកដែលនាំឲ្យមានជម្លោះពាណិជ្ជកម្មកាន់តែខ្លាំងឡើងរវាងប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេទាំងពីរ។

នេះគឺជាលើកដំបូងគិតពីឆ្នាំ២០០៨ ដែលធនាគារកណ្តាលចិនបានកំណត់តម្លៃរូបិយប័ណ្ណរបស់ខ្លួនមកនៅក្រោម

៧យន់ក្នុងមួយដុល្លារ ។ ការទម្លាក់តម្លៃរូបិយប័ណ្ណ នេះនឹងកាត់បន្ថយថ្លៃដើមនៃការនាំចេញរបស់ចិន និងធ្វើអោយសេដ្ឋកិច្ចមានការរីកចម្រើន ដើម្បីស៊ីសងគ្នាទៅនឹងអ្វីដែលបានខាតបង់នៅក្នុងចំណាត់ការនានារបស់អាមេរិក។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ផលិតកម្មឧស្សាហកម្មនៅប្រទេសចិន និងប្រទេសជប៉ុន ផលិតផលក្នុងស្រុកនៅប្រទេសម៉ាឡេស៊ី និងហុងកុង និងនិកម្មភាពរបស់កូរេខាងត្បូង។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី១២ សីហា ២០១៩

- តុល្យភាពពាណិជ្ជកម្មប៊្រុយណេ សម្រាប់ខែឧសភា
- ការវិនិយោគផ្ទាល់ពីបរទេសរបស់ហ្វីលីពីន នៅខែឧសភា
- ការរំពឹងទុកអតិផរណារបស់អតិថិជនអាមេរិក សម្រាប់ខែកក្កដា
- ការលក់រថយន្តរបស់ចិនសម្រាប់ខែកក្កដា

ថ្ងៃអង្គារ ទី១៣ សីហា ២០១៩

- គណនីចរន្តរបស់សឹង្ហបុរី សម្រាប់ត្រីមាសទី២ ឆ្នាំ ២០១៩
- ការលក់រាយរបស់ម៉ាឡេស៊ីសម្រាប់ខែកក្កដា
- ការបញ្ជាទិញឧបករណ៍ម៉ាស៊ីនរបស់ជប៉ុន សម្រាប់ខែកក្កដា
- របាយការណ៍ថវិកាអាមេរិក សម្រាប់ខែកក្កដា
- អតិផរណារបស់អាមេរិក សម្រាប់ខែកក្កដា

ថ្ងៃពុធ ទី១៤សីហា ឆ្នាំ២០១៩

- អត្រានិកម្មភាពរបស់កូរ៉េខាងត្បូង សម្រាប់ខែកក្កដា
- ផលិតកម្មឧស្សាហកម្មរបស់ចិន សម្រាប់ខែកក្កដា
- ការលក់ឡានរបស់ឥណ្ឌូនេស៊ី សម្រាប់ខែកក្កដា

ថ្ងៃព្រហស្បតិ៍ ទី១៥សីហា ២០១៩

- សន្ទស្សន៍តម្លៃផ្ទះរបស់ចិន សម្រាប់ខែកក្កដា
- តុល្យភាពពាណិជ្ជកម្មឥណ្ឌូនេស៊ី សម្រាប់ខែកក្កដា
- ផលិតកម្មឧស្សាហកម្មជប៉ុន សម្រាប់ខែកក្កដា
- ផលិតកម្មឧស្សាហកម្មអាមេរិក សម្រាប់ខែកក្កដា
- ការលក់រាយរបស់អាមេរិក សម្រាប់ខែកក្កដា

ថ្ងៃសុក្រ ទី១៦សីហា ២០១៩

- ផលិតផលក្នុងស្រុករបស់ម៉ាឡេស៊ី សម្រាប់ត្រីមាសទី២ឆ្នាំ២០១៩
- អតិផរណារបស់ម៉ាឡេស៊ី សម្រាប់ខែកក្កដា
- ការវិនិយោគភាគហ៊ុនរបស់ជប៉ុនដោយជនបរទេស ថ្ងៃទី10សីហា
- តុល្យភាពពាណិជ្ជកម្មសឹង្ហបុរីសម្រាប់ខែកក្កដា
- ផ.ស.ស.របស់ហុងកុង សម្រាប់ត្រីមាសទី២ ឆ្នាំ ២០១៩